**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

**សាលដីកា**

**តាងនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

**សភាព្រហ្មទណ្ឌ**

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ ៦៧

ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩

**សាលដីកា**

លេខ ៤៦ VII

ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម៖

១.ឯកឧត្តម [redacted] ប្រធាន

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រម

៤.លោក [redacted] ចៅក្រម

៥.លោក [redacted] ចៅក្រម

**ចៅក្រមរបាយការណ៍**

លោកស្រី [redacted]

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted]

**តំណាងមហាអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ៤២២ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ១០៣ " ក្រ॥ ប " ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមាន៖

Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ភេទប្រុស អាយុ ៤៥ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធមុខរបរអ្នកសារព័ត៌មាន ធ្លាប់រៀនថ្នាក់ទី៩ ទីកន្លែងកំណើតនៅ [redacted] ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] "រ" មានកូន ០១ នាក់ ។ (អ្នកប្តឹងសាទុក្ខ)

-លោក [redacted] សុភ័ស្ត ជាមេធាវីការពារសិទ្ធិ

ជាប់ចោទពីបទ ផ្សព្វផ្សាយព័ត៌មានមិនពិត តាមមាត្រា ១០ នៃច្បាប់ស្តីពីរបបសារព័ត៌មាន ប្រព្រឹត្តនៅភូមិប៉ាតត់ និងភូមិថ្មី ឃុំសេដា ស្រុកលំផាត់ ខេត្តរតគិរី កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៣ ។

ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជ័យ ភេទប្រុស អាយុ ៤៣ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមន្ត្រីកងរាជអាវុធហត្ថ ខេត្តរតនគិរី មានទីលំនៅបច្ចុប្បន្ន [redacted] ។

**១.អំពីអង្គហេតុ:**

កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៣ ឈ្មោះ [redacted] សុវណ្ណ បានសរសេរផ្សាយព័ត៌មានលើអត្ថបទសារព័ត៌មានរស្មីកម្ពុជាដែលមានចំណងជើងថា " អតីតមេបញ្ជាការប៉េអឹមស្រុកបរកែវកាប់ព្រៃឈើយកដីជិត១០០ហិតា ធ្វើជាកម្មសិទ្ធិ " ។ ក្រោយមកស្រាប់តែមានប្រតិកម្មផ្ទាល់ពីថ្នាក់លើ និងមានការចុះមកធ្វើអធិការកិច្ចលោក [redacted] ជ័យ ពាក់ព័ន្ធនឹងការចុះផ្សាយព័ត៌មានខាងលើហើយក៏មានការប្តឹងមកតុលាការតែម្តង ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ០៨ "ឃ" ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តរតនគិរី ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

បង្គាប់ឱ្យៈ

១.ឈ្មោះ [redacted] សុវណ្ណ ភេទប្រុស អាយុ ៤៥ឆ្នាំ ជនជាតិខ្មែរ ធ្វើការចុះផ្សាយកែតម្រូវអត្ថបទសារព័ត៌មាន ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៣ ឱ្យឈ្មោះ [redacted] ជ័យ ឱ្យត្រឹមត្រូវវិញចំនួន ០២លេខជាប់គ្នា ។

២.ឈ្មោះ [redacted] សុវណ្ណ ទទួលបន្ទុកចេញសោហ៊ុយចុះផ្សាយសាលក្រមនេះក្នុងសារព័ត៌មានរស្មីកម្ពុជា និងសារព័ត៌មាន កោះសន្តិភាព ។

៣.ឈ្មោះ [redacted] សុវណ្ណ បង់ប្រាក់ពិន័យចូលរដ្ឋចំនួន ១.០០០.០០០ (មួយលានរៀល) ។

៤.ឈ្មោះ [redacted] សុវណ្ណ បង់ប្រាក់សំណងជម្ងឺចិត្តឱ្យជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជ័យ ចំនួន ១០.០០០.០០០ (ដប់លានរៀល) គត់ ។ ឈ្មោះ [redacted] ជ័យ ទាមទារលើសពីនេះបដិសេធចោល ។

ពីបទ: ផ្សព្វផ្សាយព័ត៌មានមិនពិត ប្រព្រឹត្តនៅចំណុចភ្នំសាជាម ភូមិប៉ាតត់ និងភូមិថ្មី ឃុំសេដា ស្រុកលំផាត់ ខេត្តរតគិរី កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៣ តាមមាត្រាលេខ១០ នៃច្បាប់ស្តីពីរបបសារព័ត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ។

Scanned with CamScanner

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២០ ខែកុម្ភៈ និងប្រកាសជាសាធារណៈនៅ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០១៤ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]សុវណ្ណ និងមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។ ចំពោះមុខ ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ជ័យ ។

បើកផ្លូវ ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ០៤ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៤ របស់ឈ្មោះ[redacted]សុវណ្ណ ប្តឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ០៨ "ឃ" ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តរតនគិរី ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ១០៣ "ក្រ॥ ប" ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ទទួលបណ្តឹងឧទ្ធរណ៍លេខ ០៤ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៤ របស់ឈ្មោះ[redacted]សុវណ្ណ ទុកជាត្រឹមត្រូវតាមទម្រង់ និងតែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០៨ "ឃ" ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តរតនគិរី ទុកជាបានការពេញទាំងមូល ។

៣.សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នាថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ កំបាំងមុខជនជាប់ចោទ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ ។

បើកផ្លូវ ប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ៤២២ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ របស់ឈ្មោះ[redacted]សុវណ្ណ ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ១០៣ "ក្រ॥ ប" ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

-បានឃើញ សារណាការពារ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩ របស់ឈ្មោះ[redacted]សុវណ្ណ

-បានឃើញ សារណាតប ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៩ របស់ឈ្មោះ[redacted]ជ័យ

**២.នាពេលសវនាការ**

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានថា អំពីទម្រង់ច្បាប់ បណ្តឹងសាទុក្ខរបស់ឈ្មោះ[redacted]សុវណ្ណ លេខ ៤២២ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ ធ្វើឡើងក្នុងកំណត់ច្បាប់ ។ អំពីគតិច្បាប់ ការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ ដែលតម្កល់សាលក្រមរបស់សាលាដំបូង ទុកជាបានការដដែល គឺមានសំអាងហេតុ និងភស្តុតាងត្រឹមត្រូវតាមច្បាប់ ព្រោះថាជនជាប់ចោទដែលជាអ្នកសារព័ត៌មាន ហើយចុះផ្សាយពត៌មានមិនពិត លើដើមបណ្តឹងរដ្ឋប្បវេណីគឺជាអំពើប្រព្រឹត្តបទល្មើសដូចបទចោទមែន ។ ម៉្យាងជនជាប់ចោទក៏បានឆ្លើយទទួលកំហុសរបស់ខ្លួនផងដែរ ប៉ុន្តែអំពើប្រព្រឹត្តនេះ ពុំមានចេតនាក្នុងការ

Scanned with CamScanner

បង្ខូចឈ្មោះជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ពិតប្រាកដនោះទេ ហើយកំហុសទាំងនេះ គឺអាស្រ័យដោយការស្រាវជ្រាវរកឈ្មោះជនប្រព្រឹត្តអំពើពិតប្រាកដ មិនបានច្បាស់លាស់ប៉ុណ្ណោះ ដែលជនជាប់ចោទ និងជនរងគ្រោះពុំដែលស្គាល់គ្នា ឬមានទំនាស់និងគ្នាពីមុនមកទេ ដូចមានក្នុងសំអាងហេតុចំណុចទី២ និងទី៣ នៃសាលដីកាសាលាឧទ្ធរណ៍ស្រាប់ ។ ដូច្នេះសូមក្រុមប្រឹក្សាពិនិត្យ និងសម្រេចតាមច្បាប់ ។

-កំណត់ហេតុស្តាប់ចម្លើយ... 

-ក្រឡាបញ្ជីអានសារណាការពារ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] សុវណ្ណ

-ក្រឡាបញ្ជីអានសារណាតប ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ជ័យ

-លោក [redacted] សុភ័ស្ត ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] សុវណ្ណ បានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានពិនិត្យសំណុំរឿង និងបានស្តាប់សារណារបស់គូភាគី ដែលបានចោទប្រកាន់មកលើកូនក្តីខ្លួន ដោយពិនិត្យមើល គឺពុំមានធាតុផ្សំគ្រប់គ្រាន់នោះទេ ដោយហេតុថា នៅពេលដែលទទួលបានព័ត៌មានពីប្រជាពលរដ្ឋ កូនក្តីខ្លួនបានធ្វើការទំនាក់ទំនងទៅអាជ្ញាធរមូលដ្ឋានអំពីករណី កាប់រានដីព្រៃ ស្ថិតនៅក្នុងស្រុកលំផាត់ ក្រោយពីបានធ្វើទំនាក់ទំនងជាមួយប្រជាពលរដ្ឋ អាជ្ញាធរមូលដ្ឋាន ក៏ដូចជាឈ្មោះ [redacted] ជ័យ រួចមក កូនក្តីខ្លួនក៏បានបញ្ជូនព័ត៌មានទាំងអស់នោះទៅថ្នាក់លើ ដើម្បីធ្វើការពិនិត្យ និងធ្វើការចុះផ្សាយ ដោយស្របទៅតាមវិជ្ជាជីវៈ។ ក្រោយពេលចុះផ្សាយរួច ឈ្មោះ [redacted] ជ័យ ក៏មានប្រតិកម្មជាមួយនឹងការចុះផ្សាយ ដោយធ្វើការទំនាក់ទំនងមកខាងកាសែតរស្មីកម្ពុជា ដើម្បីឱ្យធ្វើការចុះផ្សាយកែតម្រូវឡើងវិញ ប៉ុន្តែនៅពេលដែលខាងកាសែតស្នើសុំឱ្យឈ្មោះ [redacted] ជ័យ ផ្តល់នូវឯកសារ និងភស្តុតាងនានា ដើម្បីធ្វើការកែតម្រូវនោះ គឺឈ្មោះ [redacted] ជ័យ មិនបានផ្តល់មកឱ្យខាងកាសែតនោះទេ ។ ម៉្យាងវិញ ការចុះយកព័ត៌មាន គឺកូនក្តីខ្លួនចុះយកព័ត៌មាន ក្នុងគោលបំណងផ្សព្វផ្សាយជូនសាធារណៈជន និងស្ថាប័នជំនាញ ដើម្បីចាត់វិធានការទៅតាមផ្លូវច្បាប់ ។ ក្នុងការចុះផ្សាយនេះ ខាងអង្គភាពសារព័ត៌មានក៏បានធ្វើការត្រួតពិនិត្យត្រឹមត្រូវហើយ ដោយមានឯកសារ និងមានការអះអាងច្បាស់លាស់ទើបធ្វើការចុះផ្សាយ ។ ខ្លួនស្នើសុំឱ្យ ក្រុមប្រឹក្សាជំនុំជម្រះ មេត្តាប្រានចោលសាលដីការបស់សាលាឧទ្ធរណ៍ភ្នំពេញ និងសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់សារណាបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៤២២ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ២០១៨ របស់ជនជាប់ចោទ [redacted] សុវណ្ណ ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះ មកជំនុំជម្រះបានតាម



Scanned with CamScanner

មាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា៤១៧, មាត្រា៤១៨ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា នាសវនាការនេះ ជនជាប់ចោទ [redacted] សុវណ្ណ មិនបានចូលរួមសវនាការតាម ការកោះហៅទេ ប៉ុន្តែបានដាក់សារណាបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ហើយមេធាវីការពារសិទ្ធិរបស់ជនជាប់ចោទបានចូលរួម ដូច្នេះតុលាការកំពូល អាចជំនុំជម្រះបាន។

៣-យល់ឃើញថា តាមសារណាបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ និង សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ [redacted] សុវណ្ណ នៅចំពោះមុខតុលាការកំពូល បានបដិសេធការចោទប្រកាន់ការប្រកាសពិរុទ្ធភាព និងទោស ពីបទ ផ្សាយព័ត៌មានមិនពិត ដោយលើកឡើងថា មុនពេលចេញផ្សាយលើទំព័រកាសែតរស្មីកម្ពុជា រឿងលោក [redacted] ជ័យ កាប់រានដីព្រៃរបស់រដ្ឋ នៅចំណុចភ្នំសាជាម ភូមិប៉ាគត់ និងភូមិថ្មី ឃុំសេដា ស្រុកលំផាត់ ខេត្តរតនគីរី ជនជាប់ចោទបានទទួលព័ត៌មានពីប្រជាពលរដ្ឋ ហើយបានចុះទៅដល់ទីតាំងដីនោះ ព្រមទាំងបាន ជួបសួរប្រជាពលរដ្ឋ ដែលស៊ីឈ្នួលកាប់រានដីនៅភូមិប៉ាគត់ និងទំនាក់ទំនងតាមទូរស័ព្ទសួរទៅលោក [redacted] ជ័យ ទៀតផង ប៉ុន្តែតាមចម្លើយរបស់ជនជាប់ចោទ នៅចំពោះមុខចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តរតនគីរី (ឯ.១៦) ជនជាប់ចោទ បានសារភាពថា ក្រោយពេលទទួលប្រតិកម្មពីសំណាក់លោក [redacted] ជ័យ ខ្លួនក៏បានចុះស្រាវជ្រាវម្តងទៀត ហើយរកឃើញថា តាមពិត ដីតំបន់ភ្នំសាជាម នោះ ពុំមែនឈ្មោះ [redacted] ជ័យ ជាអ្នកទិញ និងជាក់កម្មករឱ្យកាប់រានទេ តែតាមពិតឈ្មោះ [redacted] ជ័យវិញទេដែលជាអ្នកទិញ និងដាក់កម្មករឱ្យកាប់រាន ។ ចម្លើយសារភាពនេះ មានលក្ខណៈស៊ីសង្វាក់នឹងចម្លើយរបស់សាក្សីឈ្មោះ [redacted] ស្រ៊ុន ជាអភិបាលស្រុកលំផាត់,ឈ្មោះ [redacted] ជន ជាមេភូមិប៉ាគត់, ឈ្មោះ [redacted] ខាំភួន ជាមេភូមិថ្មី និងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯ.១៣ និង១២)។ ដូចនេះ តុលាការកំពូលអាចសន្និដ្ឋានបានថា មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ [redacted] សុវណ្ណ ពីបទ ផ្សាយព័ត៌មានមិនពិត ប្រព្រឹត្តកាលពីថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០១៣ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ១០ នៃច្បាប់ស្តីពីរបបសារព័ត៌មាន ឃើញថាមូលហេតុនៃបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ [redacted] សុវណ្ណ មិនត្រឹម ត្រូវតាមការកំណត់នៃមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ ។

៤.យល់ឃើញថា ការលើកឡើងរបស់ជនជាប់ចោទ ដែលថាខ្លួនមិនបានសរសេរអត្ថបទទេ តែឈ្មោះ [redacted] លុង ទេដែលជាអ្នកសរសេរនោះ តុលាការកំពូលពិនិត្យឃើញថា [redacted] លុង គ្រាន់តែជាការដាក់ឈ្មោះនៅក្រោមអត្ថបទការសែត ដែលអ្នកសរសេរមិនហ៊ានបង្ហាញ ឈ្មោះពិតប៉ុណ្ណោះ ប៉ុន្តែតាមការពិតអ្នកដែលសរសេរអត្ថបទនេះបានមកពីសេចក្តីរាយការណ៍របស់អ្នកយកពត៌មានផ្ទាល់ឈ្មោះ [redacted] សុវណ្ណ ដែលមានតួនាទីស្រាវជ្រាវ និងផ្តល់ព័ត៌មានដល់និពន្ធនាយក ហើយនិពន្ធនាយកដែលចុះផ្សាយតាមសេចក្តីរាយការណ៍របស់ភ្នាក់ងារ [redacted] សុវណ្ណ មិនមានកំហុសទេ តែជាកំហុសផ្ទាល់របស់ជនជាប់ចោទ ដែលខ្លួនបានដឹងការពិតថា [redacted] ជ័យ មិនបានប្រព្រឹត្តដូចព័ត៌មានទេ បែរជាមិនរាយការណ៍ឱ្យនិពន្ធនាយក បញ្ឈប់ការចុះផ្សាយ ឬចុះផ្សាយកែតម្រូវនូវព័ត៌មានខុសពីការពិតនោះវិញ ហើយដែលបានធ្វើ ឱ្យប៉ះពាល់ដល់

Scanned with CamScanner

កិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ដូច្នេះតុលាការកំពូល មិនអាចទទួលយកការលើកឡើងនេះថា ជាការត្រឹមត្រូវនោះទេ ។

៥-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១០៣ ក្រ ॥ "ប" ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រឹមត្រូវតាមគតិច្បាប់ ។

**ហេតុដូច្នេះ**

**សម្រេច**

១. **បដិសេធ** បណ្តឹងសាទុក្ខលេខ ៤២២ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ។

២. **តម្កល់** សាលដីកាព្រហ្មទណ្ឌលេខ ១០៣ " ក្រ ॥ ប " ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញទាំងមូល ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ ។

Scanned with CamScanner